ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 18-Oct-2013, 16:24
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(២៧)
Case File/Dossier Nº. 002/19-09-2007-ECCC-TC/SC(27)

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម គង់ ស្រីម ជាប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម Agnieszka KLONOWIECKA-MILART** |
| | **ចៅក្រម ម៉ុង មុន្នីចរិយា** |
| | **ចៅក្រម Florence Ndepele Mwachande MUMBA** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម យ៉ា ណារិន** |
| **កាលបរិច្ឆេទ៖** | **ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៣** |
| **ភាសា៖** | **ខ្មែរ/អង់គ្លេស/បារាំង** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ** |

# សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបញ្ឈប់កិច្ចដំណើរការនីតិវិធី

**សហព្រះរាជអាជ្ញា:**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ:**
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

**មេធាវីការពារក្តី ខៀវ សំផន៖**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

1. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួល *"សំណើបន្ទាន់របស់មេធាវីការពារក្ដី ខៀវ សំផន សុំឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម"* ដាក់ដោយមេធាវីការពារក្ដី ខៀវ សំផន ("មេធាវីការពារក្ដី") នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៣ ("សំណើសុំ")[1]។ សហព្រះរាជអាជ្ញា បានដាក់សារណាតបទៅនឹងសំណើនេះ នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៣ ("សារណាតប"),[2] ហើយ មេធាវីការពារក្ដីបានដាក់ឯកសារបន្ថែមទៅនឹងសំណើនេះ នៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៣ ("សេចក្ដីបន្ថែម")[3]។

2. មេធាវីការពារក្ដីបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់នូវការរំលោភជាថ្មីម្ដងទៀត លើសិទ្ធិរបស់ ខៀវ សំផន ស្នើសុំផ្អាក់ការជំនុំជម្រះនាពេលបច្ចុប្បន្ន និងបង្គាប់ឱ្យដោះលែងជាបន្ទាន់[4]។ នៅក្នុងសេចក្ដីគាំទ្រលើសំណើរបស់ខ្លួន មេធាវីការពារក្ដីលើកឡើងថា ចាប់តាំងពីការចាប់ផ្ដើមការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ពុំបានដោះស្រាយឱ្យបានស្របគ្នា និងសម្រេចច្បាស់លាស់លើបញ្ហាដែលមានលក្ខណៈសំខាន់បំផុតឡើយ ដោយបណ្ដាលឱ្យមានការពន្យារពេលពុំច្បាស់លាស់ ភាពស្រពេចស្រពិល និងការភាន់ច្រឡំ[5]។ ជាពិសេស មេធាវីការពារក្ដីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង ជាដរាបពុំបានកំណត់ច្បាស់លាស់នូវវិសាលភាពនៃសំណុំរឿង ០០២/០១[6] និងថា សាលាដំបូងបានធ្វើមានការពិបាក យល់ចំពោះការវាយតម្លៃ និងការបង្ហាញអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន និង នួន ជា ដែលត្រូវបានចោទប្រកាន់ ក្រោមបទល្មើសនៃសហឧក្រិដ្ឋកម្មរួម[7] ហើយថា សាលាដំបូងបានខកខានពុំបានកំណត់ នូវក្របខ័ណ្ឌការងារផ្នែកច្បាប់ឱ្យបានច្បាស់លាស់សម្រាប់ការរៀបចំភស្តុតាងជាឯកសារ

---

[1] ឯកសារលេខ E275/2/1/1.

[2] សារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន សុំបញ្ឈប់កិច្ចដំណើរការនីតិវិធីឯកសារលេខ E275/2/1/2, ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៣។

[3] សំណើបន្ទាន់របស់មេធាវីការពារក្ដី ខៀវ សំផន សុំឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម–*ADDENDUM*, ឯកសារលេខ E275/2/1/3, ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៣។

[4] សំណើសុំ កថាខណ្ឌ ១ និង ១០៣។

[5] សំណើសុំ កថាខណ្ឌ ៩ ដល់ ៦៨។ *សូមមើល* Addendum។

[6] សំណើសុំ កថាខណ្ឌ ១៩ ដល់ ៣៥។

[7] សំណើសុំ កថាខណ្ឌ ១៩ ដល់ ៣៦ ដល់ ៥១។

និងការផ្តល់សក្ខីកម្មរបស់សាក្សី នៅក្នុងសំណុំរឿង ០០២/០១[8]។ មេធាវីការពារក្តីបន្ថែមទៀតថា អានុភាពនៃការរំលោភបំពាន របស់អង្គជំនុំជម្រះសាលាដំបូងដែលចេះតែកើនឡើង មកលើសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិ ធម៌របស់ ខៀវ សំផន បង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពុំមានចេតនាក្នុងការស្តាប់មេធាវីការពារក្តីឡើយ ឬ ផ្តល់នូវមធ្យោបាយដើម្បីធ្វើការរៀបចំការការពារខ្លួន និងពិភាក្សាលើភស្តុតាងឱ្យមានប្រសិទ្ធិភាពឡើយ[9]។ មេធាវីការពារក្តីអះអាងថា សំណើនេះ អាចទទួលយកបាន ដោយអាស្រ័យលើអំណាចដែលភ្ជាប់ជាមួយ របស់ចៅក្រម ក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធី នៅពេលដែលមានការរំលោភកិច្ចដំណើរការនីតិវិធី[10]។

3. សហព្រះរាជអាជ្ញា ឆ្លើយតបថា សំណើនេះ បង្ហាញយ៉ាងច្បាស់ថា ពុំអាចទទួលយកបាន និងហួសពេលកំណត់[11] ហើយថា មេធាវីការពារក្តី បានធ្វើការអះអាងបញ្ជាក់ជាច្រើនលើកច្រើនសា ដែលជាការពុំផ្តល់ការគោរពដល់អង្គជំនុំជម្រះសាលាដំបូង[12]។ ហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំ អង្គជំនុំជម្រះតុលាការកំពូល បដិសេធសំណើនេះចោលទាំងស្រុង[13]។

4. យោងតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចខាងក្រោមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបើកផ្លូវឱ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗ: (ក) សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី។ (ខ) សេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឱ្យត្រួតពិនិត្យតាមផ្លូវតុលាការ អនុលោមតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង។ (គ) សេចក្តីសម្រេចអំពីវិធានការការពារតាមវិធាន ២៩(៤)(គ) នៃវិធានផ្ទៃក្នុង និង (ឃ) សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥(៦) នៃវិធានផ្ទៃក្នុង។ សេចក្តីសម្រេចផ្សេងទៀត អាចប្តឹងសាទុក្ខបានតែក្នុងករណី ដែលបានធ្វើឡើងស្របពេលជាមួយបណ្តឹងសាទុក្ខ ពីសាលក្រមលើអង្គសេចក្តី។

5. ទឡ្ហីករណ៍របស់មេធាវីការពារក្តីទាក់ទងនឹងភាពអាចទទួលយកបាន គឺកម្រិតត្រឹមការលើកឡើងនូវគោលការណ៍ទូទៅដែលថា ចៅក្រមត្រូវបានចងដោយកាតព្វកិច្ច ក្នុងការធានានូវភាពយុត្តិធម៌នៃកិច្ចដំណើរ

---

[8] សំណើសុំ កថាខណ្ឌ ១៩ និង ៥១ ដល់ ៦៨។

[9] សំណើសុំ កថាខណ្ឌ ៦៩ ដល់ ១០១។

[10] សំណើសុំ កថាខណ្ឌ ២ ដល់ ៨។ *សូមមើល* សំណើសុំ កថាខណ្ឌ ១០២។

[11] សារណាតប កថាខណ្ឌ ១ ដល់ ១៧។

[12] សារណាតប កថាខណ្ឌ ១៨។

[13] សារណាតប កថាខណ្ឌថ ១៩។

ការនីតិវិធី[14]។ នៅក្នុងការគាំទ្រនូវទឡ្ហីករណ៍របស់ខ្លួន មេធាវីការពារក្តីសំអាងលើវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលត្រូវបានអនុវត្ត និងបកស្រាយដោយអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក[15]។

6. អង្គជំនុំជម្រះតុលាការកំពូលរំលឹកឡើងវិញថា បណ្តឹងសាទុក្ខបន្ទាន់បង្ខំ ពុំត្រូវបានអនុញ្ញាតឡើយ ដោយសារតែបណ្តឹងនេះ ពុំត្រូវបានបើកទូលាយដោយយុត្តាធិការតាមវិធាន ១០៤(៤)នៃវិធានផ្ទៃក្នុង[16] និង ថា វិធាន ២១ នៃវិធានផ្ទៃក្នុង "ក្រៅពីការធានាជាស្វ័យប្រវត្តិនូវការបកស្រាយដោយផ្តល់ប្រយោជន៍ដល់ ជនជាប់ចោទនៅក្នុងវិធានផ្ទៃក្នុងគ្រប់ពេលនោះ 'វិធានេះ ត្រូវតែបកស្រាយក្នុងន័យថា ការបកស្រាយ វិធានផ្ទៃក្នុង មិនត្រូវនាំទៅរកការធ្វើឱ្យមានការប៉ះពាល់ផលប្រយោជន៍ណាមួយរបស់ជនជាប់ចោទ ដែល កើតចេញពីសិទ្ធិជាសារវ័ន្ត ដែលត្រូវបានធានានៅក្នុងលក្ខន្តិកៈ និងលិខិតុបករណ៍ផ្នែកច្បាប់នានាដែលជា ធរមាន'"[17]។

7. ដោយហេតុថា ការបញ្ចប់កិច្ចដំណើរការនីតិវិធី គឺជាដំណោះស្រាយអាចធ្វើទៅបានសម្រាប់ការរំលោភ ដែលបានបង្ហាញឱ្យឃើញលើកិច្ចដំណើរការនីតិវិធីនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមាន ការរំលោភលើសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌នេះ ដែល *តាមសេចក្តីបញ្ជាក់ដំបូង* នឹងផ្តល់យុត្តិកម្មចំពោះដំណោះស្រាយបែបនោះ ដោយយោងតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ឡើយ។ មេធាវីការពារក្តីពុំបានបង្ហាញថា ការច្រានចោលមិនទទួលយកសំណើនៅក្នុង ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ គឺជាការរំលោភសិទ្ធិជាសារវ័ន្តរបស់ ខៀវ សំផន ឬធ្វើឱ្យមានការ ប៉ះពាល់ទៀតសោត ឬត្រង់កម្រិតណាមួយ ដែលអាចនឹងតម្រូវឱ្យមានការធ្វើអន្តរាគមន៍ ដែលមាន លក្ខណៈវិសាមញ្ញឡើយ។ អង្គជំនុំជម្រះតុលាការកំពូល រំលឹកឡើងវិញថា ការជំទាស់ទាក់ទងនឹងការ ឃុំខ្លួន របស់ ខៀវ សំផន ស្ថិតក្នុងការពិចារណា ទាក់ទងនឹងយុត្តាធិការនៃបណ្តឹងសាទុក្ខតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង ហើយ ពិតណាស់ បញ្ហានេះ គឺជាកម្មវត្ថុនៃការពិនិត្យ និងជាទស្សនៈរបស់ អង្គជំនុំជម្រះតុលាការកំពូល ដោយមានការពិចារណាយ៉ាងត្រឹមត្រូវ ទាក់ទងនឹងបញ្ហាដែលជាលទ្ធផល

[14] សារណាតប កថាខណ្ឌ ២ ដល់ ៣។

[15] សំណើសុំ កថាខណ្ឌ ៤ ដល់ ៨ និង *ការយោងដែលលើកឡើងនៅទីនោះ*។

[16] សូមមើល ឧ. សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការ ប្រាស្រ័យទាក់ទងជាមួយ*ភាគីតែម្ខាង*របស់មន្ត្រីច្បាប់ជាន់ខ្ពស់ ឯកសារលេខ E154/1/1/4, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើ អៀង សារី"), កថាខណ្ឌ ១៥។

[17] សេចក្តីសម្រេចលើ អៀង សារី កថាខណ្ឌ ១៤ ដកស្រង់សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ នួន ជា និង អៀង ធីរិទ្ធ លើសំណើសុំការដោះលែងជាបន្ទាន់ ឯកសារលេខ E50/2/1/4, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ៣៩។

នៃការបំបែកកិច្ចដំណើរការនីតិវិធីនៃ សំណុំរឿង ០០២[18]។ ទាក់ទងនឹងទឡ្ហីករណ៍ដទៃទៀតនៅក្នុងសំណើនេះ ដូចជា ទាក់ទងនឹងការរៀបចំពេលវេលា និងភស្តុតាង មេធាវីការពារក្តីនៅតែអាចលើកដូចគ្នាបានដដែល នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន នៅពេលធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ប្រសិនបើមានការចោទប្រកាន់លើការប៉ះពាល់ដល់សិទ្ធិណាមួយនោះ។

8. យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេច បដិសេធលើ** សំណើនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

[18] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីសំណើរបស់ខៀវ សំផន សុំការដោះលែងជាបន្ទាន់ ឯកសារលេខ E275/2/3, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣។